# បុណ្យភ្ជុំបិណ្ឌ

រៀបរៀងដោយ កែវ ឈុន

ថ្ងៃទី ៧.តុលា ព.ស ២៥៥១ គ.ស ២០០៧

តាមទំនៀម គេធ្វើពិធីកាន់បិណ្ឌចំនួន ១៥ថ្ងៃ គឺចាប់ពីថ្ងៃ ១រោច រហូតដល់ថ្ងៃ ១៥រោច ខែភទ្របទ។ ថ្ងៃ ១រោច ដល់ថ្ងៃ ១៤រោចគឺជាថ្ងៃកាន់បិណ្ឌ រឺដាក់បិណ្ឌ រីឯថ្ងៃ ១៥ រោចគឺជាថ្ងៃភ្ជុំបិណ្ឌ ព្រោះនៅថ្ងៃនោះអ្នកស្រុកតែងតែមក ប្រជុំគ្នាធ្វើនៅក្នុងវត្តគ្រប់ៗគ្នា។ ពាក្យថា «បិណ្ឌ» មានន័យថាពំនូតបាយ ដែលគេឧទ្ទិស ដល់ខ្មោចដែលបានស្លាប់ទៅ។ សព្វថ្ងៃ បាយបិណ្ឌ គឺជាពំនូតបាយដំនើប ចំអិនជាមួយខ្ទិះដូង ហើយលាយជាមួយគ្រឿងផ្សំផ្សេងៗទៀតទៅតាមការនិយមរបស់អ្នកស្រុកក្នុងតំបន់និមួយៗ។ គេតែងដាក់បាយ បិណ្ឌក្នុងថាសមួយយកទៅវត្ត។ នៅកន្តាលបាយបិណ្ឌមានបាយបិទបូរ ដែលគេដាក់លើជើងពានតូចមួយ។ បាយបិទបូរ ដូចគ្នានឹងបាយបិណ្ឌដែរ ប៉ុន្តែ គេធ្វើវាអោយមានរាងស្រួចដូចសាជី ហើយធ្វើគំរបស្លឹកចេកគ្របពីលើ ដោយចោះកំពូលទុកសំរាប់ដោតទៀន ធូប និងផ្កា។ នៅតំបន់ខ្លះ គេធ្វើបាយបិណ្ឌដាក់ក្នុងកន្ទាងចំនួន ៨ ព័ទ្ធជុំវិញបាយបិតបូរ ហើយក្នុង កន្ទោងនិមួយៗមានពំនូតបាយបិណ្ឌពី ១ដុំទៅ ១៥ដុំ។

ក្រៅពីដង្វាយផ្សេងៗនៅក្នុងសាលាប្រជុំបុណ្យនៃវត្តគេនាំគ្នារៀបចំតុបតែងធ្វើផ្កាបិណ្ឌដែលមានរាងមូលស្រួចដូចសាជី។នៅលើកំពូលផ្កាបិណ្ឌ គេធ្វើរូបហង្សទ្រទៀន ដែលអុជ រាល់យប់នៅពេលកាន់បិណ្ឌ។ គេថា ផ្កាបិណ្ឌនេះជាតង្វាយចំពោះព្រះចូលាមណី។

មុនថ្ងៃភ្ជុំបិណ្ឌ ១ថ្ងៃ គឺ១៤រោច នៅតាមផ្ទះនិមួយៗ គេនិយមធ្វើនំអន្សម នំគម នំផ្ទៃសំរាប់យកទៅប្រគេនលោកអុទ្ទិសដល់អ្នកដែលបានស្លាប់ទៅហើយផង និងចែក ចាយដល់អ្នកជិតខាង រឺមិត្តភក្តិផង។ នៅវេលាយប់ថ្ងៃនោះនៅអែវត្តអារាមមានពិធីបង្សុកូលដល់វិញ្ញាណក្ខន្ធអ្នកដែលបាបស្លាប់ទៅហើយនិងមានការសំដែងធិមទេសនារហូតដល់ភ្លឺ។ លុះដល់ស្អែកឡើង ថ្ងៃ ១៥រោច ខែភទ្របទ ដែលជាថ្ងៃចុងក្រោយនៃពិធីកាន់បិណ្ឌហើយដែលជាថ្ងៃដែលសំខាន់ជាងគេ អ្នកស្រុកគ្រប់គ្នា នាំគ្នាធ្វើដំនើរទៅប្រជុំគ្នានៅវត្ត។ អ្នកខ្លះកាន់បាយបិណ្ឌ បាយបិតបូរ ខ្លះកាន់នំអន្សម នំគម នំផ្ទៃ និងនំចំនីផ្សេងៗទៀត ខ្លះទៀតកាន់ស្រាក់ដាក់ចង្ហាន់ទៅប្រគេនលោក។

ក្រៅពីពិធីកាន់បិណ្ឌដែលធ្វើនៅវត្ត មានពិធីសែនព្រេននៅតាមផ្ទះនិមួយៗ នៅវេលាយប់ថ្ងៃបង្ហើយនេះ។ នៅកន្តាលល្វែងផ្ទះគេក្រាលកន្ទេលមួយ ហើយដាក់ខ្នើយមួយនៅលើ ក្បាលកន្ទេលនោះ រួចយកសំពត់សមកក្រាលពីលើខ្នើយ និងកន្ទេលមួយជាន់ទៀត។ នៅជុំវិញកន្ទេល គេរៀបថាស ម្ហូប នំ ចំនី បាយបិតបូរ បាយបិណ្ឌ ផ្តិលទឹក។ រួចហើយ គ្រួសារទាំងអស់ត្រូវមកអង្គុយជុំវិញកន្ទេល និងរណ្តាប់ទាំងអស់នេះ។ លុះជួបជុំគ្នាហើយ មេគ្រួសារ

អុជធូប ទៀន អញ្ជើញវិញ្ញាណក្ខន្ធដូនតាមកពិសារក្រយានេះ អោយបានបរិបូរណ៍ ហើយសុំអោយជួយថែរក្សាកូនចៅ ដែលនៅរស់អោយបានសុខសប្បាយផង។

លុះព្រឹកព្រហាមឡើង គេរៀបចំដាក់នំចំនីក្នុងកូនទូកធ្វើអំពីដើមចេក ហើយបណ្តែតលើទឹកដើម្បីជូនដំនើរដូនតាទៅវិញ។ចំពោះកាលបរិច្ឆេទនៃការចាប់ផ្តើមធ្វើបុណ្យភ្ជុំបិណ្ឌនេះ នៅស្រុកខ្មែរពុំមានអែកសារណាមួយនិយាយអោយបានច្បាស់លាស់នោះទេ។ គេប្រទះឃើញរាជពង្សាវតាក្រុងកម្ពុជា រជ្ជកាលព្រះបាទអង្គដួង (១៨៤៨-១៨៥៩) ដែលបាននិយាយអំពីបុណ្យនេះថា៖ «ថ្ងៃមួយរោច ខែភទ្របទ កាន់បិណ្ឌក្នុងព្រះរាជវាំង ថ្ងៃ១៤រោច ព្រះរាជាទ្រង់ចេញថ្វាយព្រះបិរត (ពាក្យនេះខ្មែរយើងប្រើក្នុងព្រះរាជពិធីមួយ មានចាក់ទឹកដូងច្រូចសែនរំលឹក ដល់ពួកបុព្វបុរសក្នុងរាជត្រកូល គឺសែនរំលឹកដល់ព្រះញាតិវង្សានុវង្សដែលស្តេចទៅកាន់បរលោកហើយ) ថ្ងៃ ១៥រោច ទេសនាគាថាពាន់»។

ហេតុអ្វីបានជាគេនិយមធ្វើបុណ្យភ្ជុំបិណ្ឌក្នុង រនោច ខែ ភទ្របទ?គម្ពីរនានាខាងព្រះពុទ្ធសាសនាបានចែងថា មនុស្សដែលបានស្លាប់ទៅ តែងតែកើតក្នុងកំនើតផ្សេងៗ តាមផលនៃកម្ម។ មនុស្សអាក្រក់ដែលបានធ្វើអំពើបាបផ្សេងៗ លុះស្លាប់ទៅ តែងតែកើតនៅក្នុងកំនើតមួយហៅថា «ប្រេត»។ គម្ពីរ មិលិន្ទបញ្ហា សំដែងថាប្រេតមាន៤ពួកគឺ ៖

១. ប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម
២. ប្រេតដែលស្រេកឃ្លានអាហារជានិច្ច
៣. ប្រេតដែលភ្លើងឆេះជានិច្ច
៤. ប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃអុទ្ទិសអោយ

គឺពួកប្រេតទី ៤ នេះហើយដែលគេតែងធ្វើបុណ្យអុទ្ទិសកុសល្យអោយ។ គេនិយមរើសថ្ងៃរនោច ព្រោះពេលវេលាយប់នោះព្រះចន្ទពុំសូវមានពន្លឺ ហើយចេះតែងងឹតទៅៗ។ អោកាស នេះហើយដែលយមរាជដោះលែងពួកប្រេតទាំងនោះ អោយមករស់នៅលាយឡំជាមួយមនុស្ស ចាំទទួលភាគផលដែលបងប្អូនធ្វើបុណ្យអុទ្ទិសអោយព្រោះពួកគេខ្លាច ពន្លឺណាស់។ ប្រសិនបើក្នុងរយៈពេល ១៥ថ្ងៃ ពួកប្រេតបានដើររកគ្រប់ ៧វត្តពុំឃើញមានបងប្អូនណាធ្វើបុណ្យបញ្ជូនកុសលទៅអោយទេ ពួកប្រេតទាំងនោះ នឹងអត់ បាយ អត់ទឹក ស្រេកឃ្លាន រងទុក្ខវេទនាក្រៃលែង ហើយនឹងជេរប្រទេច ផ្តាសា មកញាតិកាទាំងឡាយអោយហិនហោចទ្រព្យសម្បត្តិ ព្រាត់ប្រាស់ម្តាយ អូវពុក ប្តីប្រពន្ធ កូនចៅ ញាតិ ផៅទាំង ៧សន្តានជាដើម។

ស្រង់ពី អរិយធម៌ខ្មែរ សំរាប់ថ្នាក់ទីបញ្ចប់ របស់ អ្នកស្រី ត្រឹង ងា សាស្ត្រាចារ្យបរិញ្ញានៅវិទ្យាល័យភ្នំដូនពេញ